# សេចក្តីណែនាំទូទៅ

1.1 **គម្រោងនេះ**

លំហាត់នេះ គឺជាផ្នែកមួយនៃការប៉ាន់ប្រមាណអំពីនិរន្តរភាពនៃសំណើគម្រោងថាមពលវារីអគ្គិសនី ដែលកំពុងចាត់ចែងឡើង ដោយក្រុមហ៊ុនថាមពលវារីអគ្គិសនី អ៊ីល ធី ឌី។ ផ្នែកនេះនៃសេចក្តីព្រាងពិធីសារ ដែលកំពុងត្រូវបានប្រើប្រាស់សម្រាប់វាយតម្លៃ គឺស្ថិតនៅក្នុងផ្នែកទី ២ : ការរៀបចំគម្រោង។ ទិដ្ឋភាពដែលកំពុងវាយតម្លៃនេះ ស្តីពី ការតាំងទីលំនៅឡើងវិញ និងការបង្វែរជីវិត្តី សម្រាប់អភិវឌ្ឍន៍។

**លំហាត់នេះ**

1. ត្រូវបែងចែកមនុស្សគ្រប់រូបនៅក្នុងបន្ទប់នេះ ចេញជាក្រុមដែល ក្រុមនីមួយៗ យ៉ាងហោចណាស់មានគ្នាប្រាំមួយនាក់ និងចាត់តាំងឱ្យមាន :
   ក. មួយរូបជាអ្នកប៉ាន់ប្រមាណ
   ខ. មួយរូបជាតំណាងក្រុមហ៊ុន
   គ. មួយរូបជាតំណាងរដ្ឋាភិបាល
   ឃ. មួយរូបជាតំណាងសហគមន៍
   បើមានសល់សមាជិកនៅក្នុងក្រុមនីមួយៗ ពួកគេអាចចូលរួមជាមួយតំណាងណាមួយខាងលើ ឬ ធ្វើជាអ្នកសង្កេតការណ៍។
2. ចូរអានឯកសារដែលបានចែកជូន។ អ្នកប៉ាន់ប្រមាណ គួរតែពិចារណាអំពីសំណួរនានាសម្រាប់សួរ និងភស្តុតាង ដែលខ្លួនចង់ទទួលបាន សម្រាប់ការដាក់ពិន្ទុ។
3. តំណាងពីក្រុមហ៊ុន រដ្ឋាភិបាល និងសហគមន៍ គួរតែស្វែងយល់ពីព័ត៌មានដែលមាននៅក្នុងដៃ ដើម្បីត្រៀមឆ្លើយនឹងសំណួរនានា និងពិចារណាអំពីភស្តុតាងអ្វីខ្លះ ដែលខ្លួនអាចលើកឡើង សម្រាប់គាំទ្រចម្លើយរៀងៗខ្លួន។
4. អ្នកប៉ាន់ប្រមាណ លើកសំណួរទៅតំណាងក្រុមហ៊ុន បន្ទាប់មកសួរទៅតំណាងរដ្ឋាភិបាល និងក្រោយមក សួរទៅតំណាងសហគមន៍ ដើម្បីព្យាយាមដាក់ពិន្ទុ។ អ្នកប៉ាន់ប្រមាណត្រូវតែដឹងថាមានភស្តុតាងអ្វីខ្លះ សម្រាប់ជាមូលដ្ឋាន នៃការដាក់ពិន្ទុ។
5. នៅពេលដែលបានធ្វើសម្ភាសចប់សព្វគ្រប់ហើយ អ្នកប៉ាន់ប្រមាណត្រូវសម្រេចថា គួរដាក់ពិន្ទុប៉ុន្មាន សម្រាប់គម្រោងនោះ និងបញ្ជាក់ពីមូលហេតុ ហើយពិភាក្សាចំណុចទាំងនេះជាមួយក្រុមទាំងមូល។
6. ក្រុមខុសៗគ្នា បង្ហាញជូនពីការកត់សំគាល់របស់ខ្លួន ដែលបានពីលំហាត់ជាក់ស្តែងនេះ។

# ព័ត៌មានសម្រាប់អ្នកវាយតម្លៃ

ផ្នែកនេះពិនិត្យមើលការតាំងទីលំនៅឡើងវិញដោយគ្មានការស្ម័គ្រចិត្ត ដែល ឬមួយជាការជម្លៀសដោយបង្ខំ (ការប្តូរទៅកន្លែងថ្មី ឬ ការបាត់បង់ទីជម្រក) ឬ ការប្តូរទីលំនៅដោយសារតែហេតុផលខាងសេដ្ឋកិច្ច (បាត់បង់ទ្រព្យសម្បត្តិ ឬ សិទ្ធិ ដែលនាំទៅរកការបាត់បង់ប្រភពប្រាក់ចំណូល ឬ មធ្យោបាយសម្រាប់ការចិញ្ចឹមជីវិត) ដែលបង្កដោយការចាប់យកដីធ្លី ដែលកើតចេញពីការអភិវឌ្ឍគម្រោងថាមពលវារីអគ្គិសនី។

<table>
<tr><th>កត្តាទាក់ទងនឹងដំណើរការ</th><th>5</th><th>4</th><th>3</th><th>2</th><th>1</th></tr>
<tr><td rowspan="6">ការប៉ាន់ប្រមាណ</td><td colspan="5">• គុណភាពនៃដំណើរការដែលនាំទៅរកការយល់ដឹងអំពីស្ថានភាពគោលខាងសេដ្ឋកិច្ច-សង្គម ក្នុងចំណោមបុគ្គលនានា ដែលអាចនឹងត្រូវប្តូរទីលំនៅ ដោយសារតែការបង្ខិតបង្ខំជាក់ស្តែង ឬ កត្តាសេដ្ឋកិច្ច បណ្តាលពីការផ្តល់ដីទៅឱ្យក្រុមហ៊ុនអភិវឌ្ឍន៍</td></tr>
<tr><td>ល្អបំផុត</td><td>ល្អណាស់</td><td>ល្អ</td><td>មិនល្អ</td><td>មិនល្អសោះ</td></tr>
<tr><td colspan="5">• ការវិភាគអំពីផលប៉ះពាល់សេដ្ឋកិច្ច-សង្គម មកលើបុគ្គលនានា ដែលអាចនឹងត្រូវចាកចោលទីលំនៅ ដោយសារការបង្ខិតបង្ខំជាក់ស្តែង ឬ កត្តាសេដ្ឋកិច្ច បណ្តាលពីការផ្តល់ដីទៅឱ្យក្រុមហ៊ុនអភិវឌ្ឍន៍</td></tr>
<tr><td>ល្អបំផុត ការវិភាគអំពីនិន្នាការ ជម្រើសនានា និងភាពពុំប្រាកដប្រជានានា</td><td>ល្អណាស់ រួមបញ្ចូលការវិភាគអំពីនិន្នាការ ជម្រើសនានា និងភាពពុំប្រាកដប្រជានានា</td><td>ល្អ ការវិភាគអំពីជម្រើសខ្លះៗ</td><td>មិនល្អ គ្មានការវិភាគអំពីជម្រើសនានា</td><td>មិនល្អសោះ</td></tr>
<tr><td colspan="5">• គុណភាពនៃដំណើរការដែលនាំទៅរកការស្វែងយល់អំពីគោលនយោបាយរបស់រដ្ឋាភិបាល និងច្បាប់ ព្រមទាំង ស្តង់ដារអន្តរជាតិ ដែលទាក់ទងនឹងការតាំងទីលំនៅឡើងវិញ ការផ្តល់ដីទៅឱ្យក្រុមហ៊ុនអភិវឌ្ឍន៍ ការទូទាត់សំណង និងតួនាទីរបស់ក្រុមហ៊ុនអភិវឌ្ឍន៍</td></tr>
<tr><td>ល្អបំផុត</td><td>ល្អណាស់</td><td>ល្អ</td><td>មិនល្អ</td><td>មិនល្អសោះ</td></tr>
<tr><td rowspan="4">ការគ្រប់គ្រង</td><td colspan="5">• គុណភាពនៃដំណើរការកសាងផែនការគ្រប់គ្រងលើការតាំងទីលំនៅឡើងវិញ ដែលរួមទាំង ផែនការសកម្មភាពតាំងទីលំនៅឡើងវិញ</td></tr>
<tr><td>ល្អបំផុត</td><td>ល្អណាស់</td><td>ល្អ</td><td>មិនល្អ</td><td>មិនល្អសោះ</td></tr>
<tr><td colspan="5">• គុណភាពនៃដំណើរការកសាងផែនការគ្រប់គ្រងការយកដីធ្លីទៅឱ្យក្រុមហ៊ុនអភិវឌ្ឍន៍</td></tr>
<tr><td>ល្អបំផុត</td><td>ល្អណាស់</td><td>ល្អ</td><td>មិនល្អ</td><td>មិនល្អសោះ</td></tr>
<tr><td rowspan="6">ការពិគ្រោះយោបល់</td><td colspan="5">• កម្រិតនៃការគោរពច្បាប់ ការគោរពចំពោះប្រពៃណី នៃដំណើការពិគ្រោះយោបល់ និងការធ្វើសេចក្តីសម្រេច ដែលគាំទ្រដល់អ្នកដែលត្រូវការឱ្យមានជំនួយគាំទ្រ សេរីភាព ដោយមានការផ្តល់ដំណឹងជាមុនបានគ្រប់គ្រាន់</td></tr>
<tr><td>ល្អបំផុត</td><td>ល្អណាស់</td><td>ល្អ</td><td>មិនល្អ</td><td>មិនល្អសោះ</td></tr>
<tr><td colspan="5">• កម្រិត ដែលបុគ្គលនានាអាចត្រូវប្តូរទីលំនៅ ដោយសារតែការបង្ខិតបង្ខំជាក់ស្តែង ឬ ដោយសារកត្តាសេដ្ឋកិច្ច បណ្តាលពីការផ្តល់ដីទៅឱ្យក្រុមហ៊ុនអភិវឌ្ឍន៍ និងកម្រិតដែលសហគមន៍មូលដ្ឋាន ត្រូវបានអនុញ្ញាតឱ្យចូលរួមនៅក្នុងការបង្កើតទម្រង់នៃដំណើរការពិគ្រោះយោបល់ និងការធ្វើសេចក្តីសម្រេចអំពីបញ្ហានានាដែលមានការពាក់ព័ន្ធជាមួយខ្លួន</td></tr>
<tr><td>ល្អបំផុត</td><td>ល្អណាស់</td><td>ល្អ</td><td>មិនល្អ</td><td>មិនល្អសោះ</td></tr>
<tr><td colspan="5">• គុណភាពនៃយន្តការដោះស្រាយបណ្តឹងសារទុក</td></tr>
<tr><td>ល្អបំផុត</td><td>ល្អណាស់</td><td>ល្អ</td><td>មិនល្អ</td><td>មិនល្អសោះ</td></tr>
<tr><th>កត្តាទាក់ទងនឹងការប្រព្រឹត្តទៅ</th><th>5</th><th>4</th><th>3</th><th>2</th><th>1</th></tr>
<tr><td>ការគាំទ្រនៃអ្នក</td><td colspan="5">• កម្រិតនៃការគាំទ្រពីបុគ្គលនានា ដែលអាចត្រូវប្តូរទីលំនៅ ដោយសារតែការបង្ខិតបង្ខំជាក់ស្តែង ឬដោយសារកត្តាសេដ្ឋកិច្ច ពីសំណាក់ការផ្តល់ដីទៅឱ្យក្រុមហ៊ុនអភិវឌ្ឍន៍ និងពីសហគមន៍មូលដ្ឋានដែលជាម្ចាស់ដី</td></tr>
</table>

| **ពាក់ព័ន្ធ** | ការឯកភាពទាំងស្រុងជាមួយកិច្ចព្រមព្រៀងតាមផ្លូវច្បាប់ | ការឯកភាពបានទូលាយជាមួយក្រុមមនុស្ស និងក្រុមជំទាស់ចំបង១ស្មើរទាំងអស់ | ការឯកភាពជាទូទៅជាមួយក្រុមមនុស្សភាគច្រើន និងគ្មានការជំទាស់ធំដុំទេ | ការឯកភាពខ្លះ១ជាមួយក្រុមមនុស្សខ្លះ១ និងអ្នកជំទាស់មកពីក្រុមខ្លះ១ | គ្មានការឯកភាព និងមានការជំទាស់ពីក្រុមមនុស្សជាច្រើន |
|---|---|---|---|---|---|
| **ការអនុវត្តតាម** | • ការអនុវត្តតាមគ្រប់លក្ខខណ្ឌនៃច្បាប់ដែលពាក់ព័ន្ធ ឬ ការប្តេជ្ញានានាដែលបានប្រកាសជាសាធារណៈ ដែលរួមទាំង សិទ្ធិសម្រាប់បុគ្គលនានាដែលអាចត្រូវប្តូរទីលំនៅដោយសារតែការបង្ខិតបង្ខំជាក់ស្តែង ឬ កត្តាសេដ្ឋកិច្ច ដែលបណ្តាលពីការផ្តល់ដីទៅឱ្យក្រុមហ៊ុនអភិវឌ្ឍន៍ | | | | |
| | ល្អបំផុត | ល្អណាស់ | ល្អ | មិនល្អ | មិនល្អសោះ |
| **ការគោរពតាមផែនការ** | • ការគោរពតាមផែនការគ្រប់គ្រងនានា ឬការចាត់ចែងនានាដែលបានគ្រោងឡើង ទាក់ទងនឹងការតាំងទីលំនៅឡើងវិញ ឬការផ្តល់ដីទៅឱ្យក្រុមហ៊ុនអភិវឌ្ឍន៍ | | | | |
| | ល្អបំផុត | ល្អណាស់ | ល្អ | មិនល្អ | មិនល្អសោះ |
| **ប្រសិទ្ធិភាព** | • កិច្ចប្រឹងប្រែងនានា តាមរយៈការជ្រើសរើសយកទីតាំង និងការបង្កើតប្លង់សមស្រប ដើម្បីបញ្ចៀស ឬ កាត់បន្ថយការប្តូរទីលំនៅ ដោយសារតែការបង្ខិតបង្ខំជាក់ស្តែង ឬ កត្តាសេដ្ឋកិច្ច បណ្តាលពីការផ្តល់ដីទៅឱ្យក្រុមហ៊ុនអភិវឌ្ឍន៍ | | | | |
| | ភស្តុតាងច្បាស់លាស់ដែលបង្ហាញពីការកាត់បន្ថយយ៉ាងច្រើនតាមរយៈប្លង់ចុងក្រោយ | ភស្តុតាងច្បាស់លាស់ដែលបង្ហាញពីការកាត់បន្ថយតាមរយៈប្លង់ចុងក្រោយ | ភស្តុតាងខ្លះ១ដែលបង្ហាញពីការកាត់បន្ថយ តាមរយៈប្លង់ចុងក្រោយ | ភស្តុតាងតិចតួចដែលបង្ហាញពីការកាត់បន្ថយ | គ្មានភស្តុតាងដែលបង្ហាញពីការកាត់បន្ថយ |
| | • ភវនីយភាពនៃការកែលម្អទាន់ពេលវេលា នូវស្តង់ដារនៃការរស់នៅ ក្នុងចំណោមបុគ្គលនានា ដែលអាចត្រូវប្តូរទីលំនៅ ដោយសារតែការបង្ខិតបង្ខំជាក់ស្តែង ឬ កត្តាសេដ្ឋកិច្ច បណ្តាលពីការផ្តល់ដីទៅឱ្យក្រុមហ៊ុនអភិវឌ្ឍន៍ | | | | |
| | ខ្ពស់ខ្លាំងណាស់ | ខ្ពស់ | ល្អ | តិចតួច | គ្មាន |
| | • ភវនីយភាពនៃការកែលម្អទាន់ពេលវេលា នូវការចិញ្ចឹមជីវិតរបស់បុគ្គលនានា ដែលអាចត្រូវប្តូរទីលំនៅ ដោយសារតែការបង្ខិតបង្ខំជាក់ស្តែង ឬ កត្តាសេដ្ឋកិច្ច បណ្តាលពីការផ្តល់ដីទៅឱ្យក្រុមហ៊ុនអភិវឌ្ឍន៍ | | | | |
| | ខ្ពស់ខ្លាំងណាស់ | ខ្ពស់ | ល្អ | តិចតួច | គ្មាន |

# ព័ត៌មានសម្រាប់តំណាងក្រុមហ៊ុន

រូបអ្នកកំពុងគ្រប់គ្រងដំណើរការវាយតម្លៃហេតុប៉ះពាល់សង្គមសម្រាប់គម្រោងថាមពលវារីអគ្គិសនី ក្នុងនាមក្រុមហ៊ុនអភិវឌ្ឍន៍មួយ ពោលគឺក្រុមហ៊ុនថាមពលវារីអគ្គិសនី អិលធីឌី។ ជាការឆ្លើយតបនឹងសំណួរដែលបានសួរ អ្នកត្រូវផ្ដល់ព័ត៌មានទៅឱ្យអ្នកប៉ាន់ប្រមាណ :

## 1. ការប៉ាន់ប្រមាណ

ក្រុមហ៊ុនថាមពលវារីអគ្គិសនី អិល ធី ឌី បានបញ្ចប់ដំណើរការវាយតម្លៃហេតុប៉ះពាល់សង្គម សម្រាប់គម្រោងថាមពលវារីអគ្គិសនី និងបានដាក់ជូនរបាយការណ៍ហេតុប៉ះពាល់សង្គម (SIA) កាលពីបីខែមុន។ របាយការណ៍ SIA បានបង្ហាញថា គ្រួសារ ចំនួន 11 (មនុស្ស 60) ទំនងជារងគ្រោះពីការបង្វែរដីសម្រាប់អភិវឌ្ឍន៍។ អ្នកជំនាញការឯករាជ្យ បានធ្វើការសិក្សាលំអិតមួយអំពីសេដ្ឋកិច្ច-សង្គមនៃគ្រួសារទាំងនេះ ហើយផលប៉ះពាល់បណ្ដាលពីការផ្ដល់ដីនេះ ត្រូវបានធ្វើអត្តសញ្ញាណ។ គ្រួសារចំនួន 8 ក្នុងចំណោមគ្រួសារ ទាំងនេះ ត្រូវប្ដូរទីលំនៅ ហើយ 3 គ្រួសារផ្សេងទៀត នឹងត្រូវរងផលប៉ះពាល់បណ្ដាលពីកត្តាសេដ្ឋកិច្ច ព្រោះថាផ្នែកជាច្រើននៃកសិដ្ឋាន របស់ពួកគេ នឹងត្រូវលិចលង់ដោយសារអាងទឹកដែលនឹងកើតឡើង។ អ្នកត្រូវពិនិត្យមើលរបាយការណ៍ SIA និងបង្ហាញអំពីផ្នែកនេះ និងឧបសម្ព័ន្ធ ដែលបង្ហាញពីផលប៉ះពាល់ចំពោះគ្រួសារទាំង 11។ អ្នកក៏ត្រូវបង្ហាញផងដែរនូវរបាយការណ៍មួយ ដែលរូបអ្នកបានរៀប ចំឡើង ដែលរបាយការណ៍នោះបង្ហាញពីគោលនយោបាយរបស់រដ្ឋាភិបាល និងច្បាប់ ដែលទាក់ទងនឹងការតាំងទីលំនៅថ្មី ការផ្ដល់ដីទៅឱ្យក្រុមហ៊ុន និងការតាំងទីលំនៅថ្មី។

## 2. ការកសាងផែនការគ្រប់គ្រង

អ្នកផ្ដល់យោបល់ថា គ្មានដំណើរការកសាងផែនការគ្រប់គ្រងណាមួយទាក់ទងនឹងការផ្ដល់ដីទៅឱ្យក្រុមហ៊ុនអភិវឌ្ឍន៍ឡើយ។ អ្នកទទួលបានដីថ្មី ទំនប់ត្រូវបានសាងសង់ ទឹកជំនន់នឹងចាប់ផ្ដើម ហើយដីថ្មីនឹងត្រូវជន់លិច។ ផែនការសកម្មភាពតាំងទីលំនៅឡើងវិញ សម្រាប់ការប្ដូរទីលំនៅគ្រួសារចំនួន 8 កំពុងស្ថិតក្រោមការរៀបចំ ហើយអ្នកបង្ហាញពីសេចក្ដីព្រាងសម្ងាត់មួយដល់អ្នកប៉ាន់ប្រមាណ។ ផែនការនោះចែងអំពីក្របខ័ណ្ឌទូទាត់សំណង ជំនួយសម្រាប់ការតាំងទីលំនៅថ្មី និងការចាត់ចែងសម្រាប់ការចិញ្ចឹមជីវិត ថវិកា និងកាលវិភាគម្រាប់អនុវត្ត ការទទួលខុសត្រូវលើការចាត់ចែង និងដំណើរការតាមដាន និងវាយតម្លៃ។

## 3. ការពិគ្រោះយោបល់

អ្នកផ្ដល់យោបល់ថា ក្រុមហ៊ុនថាមពលវារីអគ្គិសនី អិល ធី ឌី បានធ្វើការពិគ្រោះយោបល់យ៉ាងវែង ដើម្បីពិគ្រោះយោបល់លើសំណើគម្រោង ជាមួយអ្នកដែលទំនងជានឹងរងគ្រោះដោយសារគម្រោងនេះ។ នៅដំណាក់កាលដើមដំបូង មានការប្រជុំជាសាធារណៈមួយចំនួន ដែលបើកចំហសម្រាប់ការផ្ដល់យោបល់ពីមនុស្សទាំងឡាយដែលមានចំណាប់អារម្មណ៍។ នៅពេលដែលក្រុមហ៊ុននេះយល់ដឹងបានប្រសើរជាងមុន អំពីគ្រួសារនានាដែលនឹងរងគ្រោះដោយសារការបង្វែរដីសម្រាប់អភិវឌ្ឍន៍ ក្រុមហ៊ុនបានចាត់តាំងមន្ត្រីសម្រាប់ធ្វើទំនាក់ទំនងដោយផ្ទាល់ជាមួយគ្រួសារនានាដែលពាក់ព័ន្ធទាំងនោះ។ ក្រុមហ៊ុនបានផ្ដល់ព័ត៌មានក្រោមទម្រង់ដែលងាយស្រួលយល់ដល់គ្រួសារទាំងនោះ និងបានធ្វើការពិភាក្សាជាច្រើនលើក ដែលធ្វើឱ្យគ្រួសារទាំងនោះបានស្វែងយល់អំពីជម្រើសទាំងអស់របស់ពួកគេ និងមានគោលដៅស្វែងរកចំណាត់ការល្អបំផុតសម្រាប់គ្រួសារនីមួយៗ។ គ្រួសារទាំងឡាយដែលរងការប៉ះពាល់ ដោយសារត្រូវក្រុមហ៊ុនយកដីសម្រាប់អភិវឌ្ឍន៍ អាចទាក់ទងជាមួយមន្ត្រីទំនាក់ទំនងសហគមន៍ នៅពេលណាមួយក៏បាន ទាក់ទងនឹងរាល់កង្វល់ ឬ បញ្ហានានា ហើយមន្ត្រីទាំងនោះ រក្សាទុករាល់កំណត់ត្រាអំពីការពាក់ព័ន្ធទាំងនេះនិងលទ្ធផលនានា ដើម្បីបង្ហាញថា នេះគឺជាយន្តការទំនាក់ទំនងមួយដ៏មានប្រយោជន៍។

4. **ការគាំទ្ររបស់អ្នកពាក់ព័ន្ធ**

អ្នកផ្ដល់យោបល់ថា កិច្ចព្រមព្រៀងនានាស្ដីពីការទូទាត់សំណង និងការចាត់ចែងតាំងទីលំនៅថ្មី កំពុងស្ថិតក្រោមការចរចា ដូច្នេះ អ្នកមិនអាចផ្ដល់យោបល់បានដាច់ស្រេចអំពីរឿងនេះឡើយ។ បើទោះជាមានការជំទាស់ពីដំបូងចំពោះការអនុវត្តគម្រោងនេះ និងបើទោះជាមានការព្រួយបារម្ភជាច្រើនក៏ដោយ គេពុំឃើញមានការជំទាស់ធំដុំពីក្នុងចំណោមអ្នកដែលរងគ្រោះដោយផ្ទាល់ពីបញ្ហានៃការបង្វែរដីសម្រាប់អភិវឌ្ឍន៍ឡើយ។

5. **ការអនុវត្តតាម**

អ្នកបង្ហាញពីរបាយការណ៍ដែលបានរៀបចំឡើងនៅក្នុងដំណើរការប៉ាន់ប្រមាណ ដែលឆ្លើយតបទៅនឹងគ្រប់គោលនយោបាយរបស់រដ្ឋាភិបាល និងច្បាប់នានាដែលទាក់ទងនឹងការផ្ដល់ដីទៅឱ្យក្រុមហ៊ុនអភិវឌ្ឍន៍ ការតាំងទីលំនៅថ្មី និងការទូទាត់សំណង និងផ្ដល់ការធានាអះអាងចំពោះអ្នកប៉ាន់ប្រមាណថា រាល់លទ្ធផលដែលទទួលបាន នឹងមានភាពស្របគ្នាជាមួយលក្ខខណ្ឌទាំងនេះ។

6. **ការគោរពតាមផែនការនានា**

អ្នកជឿថាប្រការនេះ នឹងពាក់ព័ន្ធនៅគ្រប់ដំណាក់កាលទាំងអស់។

7. **ប្រសិទ្ធិភាព**

អ្នកបង្ហាញថា នៅក្នុងឯកសារEIA/SIA មានជម្រើសមួយចំនួនសម្រាប់ការជ្រើសយកទីតាំង និងប្លង់គម្រោង ហើយប្រការនេះត្រូវបានគិតគូរ ធៀបនឹងបញ្ហាហិរញ្ញវត្ថុ បច្ចេកទេស សង្គម និងបរិស្ថាន។ ការជ្រើសយកទីតាំង និងប្លង់គម្រោងជាចុងក្រោយ មិននាំឱ្យមានការបង្វែរដី និងការតាំងទីលំនៅថ្មីតិចជាងមុនឡើយ ប៉ុន្តែវាជាទីតាំងភូមិសាស្ត្រដែលសមស្របបំផុតសម្រាប់ការសង់ទំនប់។ អ្នកផ្ដល់យោបល់ថា អ្នកអាចបង្ហាញរបាយការណ៍បច្ចេកទេសភូមិសាស្ត្រ។ អ្នកបង្ហាញនៅក្នុងសេចក្ដីព្រាងផែនការសកម្មភាព សម្រាប់ការតាំងទីលំនៅជាថ្មី ដែលគូសបញ្ជាក់អំពីចំណុចដៅនានា ដែលទាក់ទងនឹងស្ដង់ដារនៃការរស់នៅ និងការចិញ្ចឹមជីវិតរបស់ក្រុមគ្រួសារដែលអាចនឹងត្រូវបង្ខំឱ្យធ្វើការប្ដូរទីលំនៅ ឬត្រូវប្ដូរទីលំនៅដោយសារតែកត្តាសេដ្ឋកិច្ច បណ្ដាលពីការផ្ដល់ដីទៅឱ្យក្រុមហ៊ុនអភិវឌ្ឍន៍។ ចំណុចដៅទាំងនេះ មានគោលដៅបង្កើនស្ដង់ដារនៃការរស់នៅ និងការចិញ្ចឹមជីវិត ឱ្យដល់កម្រិតមួយ ដែលស្របជាមួយកម្រិតនៅមុនពេលមានគម្រោង នៅក្នុងរយៈពេល 6ខែ នៃការប្ដូរទីលំនៅ ហើយក្នុងរយៈពេល 12ខែ អាចកើនហួសពីកម្រិតនៅមុនពេលមានគម្រោង។ អ្នកបង្ហាញអំពីការប្ដេជ្ញា ដើម្បីធ្វើការតាមដាន និងការងារបន្តដែលមានចែងនៅក្នុងសេចក្ដីព្រាងផែនការនោះ។

# ព័ត៌មានសម្រាប់តំណាងរដ្ឋាភិបាល

រូបអ្នកគឺជាមន្ត្រីធ្វើការប៉ាន់ប្រមាណសម្រាប់រដ្ឋាភិបាលនៅថ្នាក់ជាតិ។ រូបអ្នកបានរៀបចំគោលការណ៍ណែនាំសម្រាប់ការវាយតម្លៃហេតុប៉ះពាល់សង្គម (SIA) សម្រាប់សំណើគម្រោងវារីអគ្គិសនី និងបានពិនិត្យមើលរបាយការណ៍ SIA ដែលបានដាក់ជូនមកការិយាល័យរបស់អ្នក។ ជាការឆ្លើយតបទៅនឹងសំណួរដែលបានសួរ អ្នកត្រូវផ្តល់ព័ត៌មានដូចខាងក្រោមនេះទៅដល់អ្នកប៉ាន់ប្រមាណ :

## 1. ការវាយតម្លៃ

រូបអ្នកផ្តល់យោបល់ថា របាយការណ៍ SIA ដែលបានដាក់ជូនដោយក្រុមហ៊ុនថាមពលវារីអគ្គិសនី អ៊ីលធីឌី បានធ្វើតាមគោលការណ៍ណែនាំនានា ដែលកំណត់ដោយរដ្ឋាភិបាលនៅថ្នាក់ជាតិ។ អ្នកបានធ្វើការផ្ទៀងផ្ទាត់ដោយឯករាជ្យមួយ អំពីស្ថានភាពគោលខាងសេដ្ឋកិច្ច-សង្គម នៃក្រុមគ្រួសារទាំងឡាយ ដែលនឹងត្រូវប្តូរទីលំនៅ ហើយពុំបានឃើញបញ្ហាចំបងៗទាក់ទងជាមួយការងាររបស់ក្រុមហ៊ុនវារីអគ្គិសនី អ៊ីលធីឌី ឡើយ។ រូបអ្នកផ្តល់យោបល់ថា ក្រុមហ៊ុនបានពិចារណាអំពីជម្រើសខ្លះៗ ប៉ុន្តែមិនបានធ្វើការវិភាគច្រើនអំពីនិន្នាការ និងភាពមិនប្រាកដប្រជាឡើយ ដែលទាក់ទងនឹងការវិភាគផលប៉ះពាល់ខាងសេដ្ឋកិច្ច-សង្គម។ អ្នកជឿថា ក្រុមហ៊ុនអភិវឌ្ឍន៍មានការយល់ដឹងបានល្អ អំពីគោលនយោបាយរបស់រដ្ឋាភិបាល និងច្បាប់នានា ប៉ុន្តែមិនអាចផ្តល់យោបល់ថាតើពួកគេយល់ដឹងអំពីស្តង់ដារអន្តរជាតិ ដែលទាក់ទងនឹងការតាំងលំនៅថ្មី ការយកដីសម្រាប់អភិវឌ្ឍន៍ និងការទូទាត់សំណងឡើយ។

## 2. ការកសាងផែនការគ្រប់គ្រង

អ្នកបានដឹងថាក្រុមហ៊ុននេះកំពុងធ្វើការលើផែនការសកម្មភាពសម្រាប់ការតាំងទីលំនៅជាថ្មី ប៉ុន្តែនៅពុំទាន់បានឃើញផែនការនោះនៅឡើយទេ។

## 3. ការពិគ្រោះយោបល់

អ្នកដឹងថា ក្រុមហ៊ុនវារីអគ្គិសនី អ៊ីល ធី ឌី បានចាត់ចែងឱ្យមានការប្រជុំជាសាធារណៈជាច្រើនលើក អំពីគម្រោងនេះ និងបានចាត់តាំងមន្ត្រីទំនាក់ទំនងសហគមន៍ ដើម្បីឱ្យធ្វើការជាមួយគ្រួសារនានា។ រដ្ឋាភិបាលមានតំណាងនានានៅក្នុងការប្រជុំទាំងនោះ និងបានរក្សាការទាក់ទងជាមួយមន្ត្រីទំនាក់ទំនងសហគមន៍។

## 4. ការគាំទ្ររបស់អ្នកពាក់ព័ន្ធ

អ្នកដឹងថា មានការព្រួយបារម្ភជាច្រើនក្នុងចំណោមអ្នកដែលទទួលរងគ្រោះដោយផ្ទាល់ទាំងនេះ ប៉ុន្តែអ្នកមិនបានដឹងអំពីជំហរប្រឆាំងដាច់ខាតពីបុគ្គលណាម្នាក់ៗឡើយ។ ទោះជាយ៉ាងណាក៏ដោយ គេមានការព្រួយបារម្ភជាច្រើន អំពីកង្វល់ដែលលើកឡើងដោយ NGOs អន្តរជាតិ ដែលជំទាស់នឹងគម្រោងនេះ ដោយសារពួកគេគិតថា មានការអភិវឌ្ឍថាមពលវារីអគ្គិសនីជាច្រើនរួចមកហើយនៅក្នុងអាងទន្លេនេះ។

## 5. ការអនុវត្តតាម

អ្នកដឹងថា ក្រុមហ៊ុននេះមានប្រវត្តិនៃការអនុវត្តតាមបានយ៉ាងល្អប្រសើរ និងជឿថា គួរគេបានគិតគូរអំពីកាតព្វកិច្ចរបស់ខ្លួនបានយ៉ាងហ្មត់ចត់។

## 6. ការគោរពតាមផែនការនានា

ផែនការសកម្មភាពសម្រាប់ការតាំងទីលំនៅថ្មីត្រូវបានពន្យាពេលអនុវត្ត ហើយប្រការនេះទំនងជាត្រូវបានគ្រោងដាក់ជូនទៅរដ្ឋាភិបាលនៅក្នុងរយៈពេលបីខែមុននេះ ជាកាលបរិច្ឆេទដែលក្រុមហ៊ុននេះបានពោលថា ពួកគេនឹងដាក់ជូនរបាយការណ៍នេះ។

## 7. ប្រសិទ្ធិភាព

អ្នកជឿថា ការជ្រើសយកទីតាំង និងគំរូប្លង់ចុងក្រោយ បានគិតគូរអំពីកត្តាជាច្រើន ដែលរួមទាំង កត្តាសង្គមផងដែរ ។ ការពិចារណានោះមិនបានគេចវេសពីការគិតគូរដល់ផលប៉ះពាល់សង្គមឡើយ ប៉ុន្តែវាមិនមែនជាសេណារីយ៉ូអាក្រក់បំផុតនៃផលប៉ះពាល់សង្គមនោះទេដែរ ។

អ្នកមិនបានដឹងទេថា មានអ្វីខ្លះនៅក្នុងផែនការសកម្មភាពតាំងទីលំនៅជាថ្មី ដូច្នេះអ្នកមិនអាចផ្តល់យោបល់លើលទ្ធភាពនៃការកែលម្អស្តង់ដារនៃការរស់នៅ ឬការចិញ្ចឹមជីវិតរបស់អ្នកដែលនឹងត្រូវផ្លាស់ប្តូរទីលំនៅនោះឡើយ ។

# ព័ត៌មានសម្រាប់តំណាងមកពីសហគមន៍

រូបអ្នក គឺជាកសិករមួយរូប ដែលនឹងបាត់បង់ដីកសិដ្ឋានមួយចំណែក ដោយសារតែការជន់លិច បណ្ដាលពីសំណើគម្រោង វារីអគ្គិសនីនេះ ជាការឆ្លើយតបចំពោះសំណួរដែលបានលើកឡើង រូបអ្នកត្រូវផ្ដល់ព័ត៌មានដូចតទៅ ដល់អ្នកប៉ាន់ប្រមាណ :

1. **ការវាយតម្លៃ**

រូបអ្នកមានការជំទាស់ខ្លះៗ ទៅនឹងការប៉ាន់ប្រមាណអំពីហេតុប៉ះពាល់សេដ្ឋកិច្ច-សង្គមដែលបានធ្វើឡើង ដោយសារអ្នក គ្រោងធ្វើការវិនិយោគដើម្បីអភិវឌ្ឍភាគចំណែកនោះនៃដីកសិដ្ឋាន ដើម្បីដាំដំណាំថ្មីៗ ហើយសព្វថ្ងៃនេះឱកាសនោះនឹងត្រូវបាត់បង់ ។

2. **ការកសាងផែនការគ្រប់គ្រង**

អ្នកគិតថា រាល់ការគិតគូរត្រូវបានផ្ដោតតែលើគ្រួសារនានាដែលបានប្ដូរទីលំនៅជាក់ស្ដែង និងផែនការសកម្មភាពសម្រាប់ការតាំងទីលំនៅជាថ្មី ។ អ្នកដឹងថា អ្នកនឹងធ្វើការគណនាអំពីការទូទាត់សំណងខ្លះៗ ចំពោះដីធ្លីដែលបានបាត់បង់ ប៉ុន្តែអ្នកមិនដឹងទេថា ការទូទាត់នេះនឹងធ្វើឡើងនៅពេលណា និងដោយរបៀបណា និងមិនដឹងថានឹងមានអ្វីកើតឡើងជាបន្តឡើយ ទាក់ទងនឹងស្តង់ដារនៃការរស់នៅ និងការចិញ្ចឹមជីវិតរបស់អ្នក ។

3. **ការពិគ្រោះយោបល់**

អ្នកបានចូលរួមនៅក្នុងការប្រជុំជាសាធារណៈ និងបានធ្វើការអង្កេតដោយទីប្រឹក្សានានា នៅពេលដែលពួកគេរៀបចំរបាយការណ៍ SIA ។ អ្នកមិនដែលបានឃើញរបាយការណ៍ SIA ដោយផ្ទាល់នោះឡើយ ដោយសារអ្នកពុំអាចប្រើប្រាស់អ៊ីនធឺណិត ។ អ្នកបានព្យាយាមទាក់ទងជាមួយមន្ត្រីទំនាក់ទំនងសង្គមដែរ ប៉ុន្តែគាត់តែងតែជាប់រវល់ និងមិនបានឆ្លើយតបឡើយ ។

4. **ការគាំទ្ររបស់អ្នកពាក់ព័ន្ធ**

អ្នកមិនជំទាស់នឹងគម្រោងនេះទេ ប៉ុន្តែចង់ធ្វើឱ្យមានការធានាថានឹងបានទទួលការទូទាត់សំណងបានត្រឹមត្រូវ ។ អ្នកមិនត្រឹមតែចង់បានការទូទាត់នោះទេ ប៉ុន្តែអ្នកចង់ដីនៅកន្លែងថ្មីមួយ ដែលអ្នកអាចអនុវត្តផែនការរបស់អ្នក ដើម្បីបង្កើតមុខជំនួញប្រចាំគ្រួសាររបស់អ្នកផងដែរ ។

5. **ការអនុវត្តតាម**

អ្នកមិនមានអារម្មណ៍ថា រូបអ្នកអាចផ្ដល់យោបល់លើកិច្ចការនេះបានទេ ប៉ុន្តែសង្ឃឹមថា រដ្ឋាភិបាលនឹងតម្រូវឱ្យក្រុមហ៊ុនផ្ដល់ដីនៅកន្លែងថ្មី ។

6. **ការគោរពតាមផែនការនានា**

អ្នកមិនមានអារម្មណ៍ថាអាចផ្ដល់យោបល់លើកិច្ចការនេះបានឡើយ ។

7. **ប្រសិទ្ធិភាព**

ជម្រើសនៃការរើសយកទីតាំង គឺជាជម្រើសតែមួយក្នុងចំណោមជម្រើសនានាដែលបានពិចារណាថា មានឥទ្ធិពលមកលើរូបអ្នកដោយផ្ទាល់ ។ អ្នកមិនចង់ឱ្យគេយកចំណែកដីកសិដ្ឋានរបស់ខ្លួនឡើយ ។

អ្នកបានឮថា ក្រុមហ៊ុននេះពោលថា គម្រោងនេះនឹងផ្ដល់ប្រយោជន៍សម្រាប់មនុស្សគ្រប់រូប ប៉ុន្តែអ្នកមិនជឿឡើយ រហូតទាល់តែបានឃើញសំណើជាក់លាក់មួយនៅចំពោះមុខផ្ទាល់ សម្រាប់ការទូទាត់ជាការដោះដូរដី ។